00827242

E212/1

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 05 / 07 / 2012
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ : សាធារណៈ / Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**ចម្លើយតបទៅនឹងសំណើរបស់ នួន ជា សុំឲ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ ទាក់ទិននឹងការកោះហៅសាក្សីដែលបានស្នើឡើងដោយមេធាវីការពារក្តី**

| <u>ដាក់ដោយ៖</u> | <u>ផ្ញើជូន៖</u> | <u>ចម្លងជូន៖</u> |
|---|---|---|
| **សហព្រះរាជអាជ្ញា÷** | **អង្គជំនុំជម្រះសាលាដំបូង÷** | **ជនជាប់ចោទ÷** |
| ជា លាង | ចៅក្រម **និល ណុន** ជាប្រធាន | អៀង សារី |
| Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | នួន ជា |
| | ចៅក្រម **យ៉ា សុខន** | ខៀវ សំផន |
| | ចៅក្រម Jean-Marc LAVERGNE | |

E212/1

សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU FORT

សុន អរុណ

Michiel PESTMAN
Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN
Jacques VERGÈS

00827244

E212/1

សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

# I. សេចក្តីផ្តើម

1. នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១២ មេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") បានដាក់*សំណើសុំឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ ទាក់ទិននឹងការកោះហៅសាក្សីដែលបានស្នើឡើងដោយមេធាវីការពារក្តី* ("សំណើ")។ សហព្រះរាជអាជ្ញាបានទទួលសំណើនេះនៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១២។ មេធាវីការពារក្តីបានស្នើសុំឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈមួយ អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង ("វិធាន") ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") ស្តាប់សេចក្តីសន្និដ្ឋានពីភាគីនានាស្តីពីការជ្រើសរើសសាក្សី និងអ្នកជំនាញដែលបានស្នើឡើងដោយមេធាវីការពារក្តី។

2. តទៅនេះសហព្រះរាជអាជ្ញាសូមធ្វើការឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីការពារក្តី។ សហព្រះរាជអាជ្ញាសូមលើកឡើងថា សវនាការផ្ទាល់មាត់ជាសាធារណៈបន្ថែមទៀតពុំមានការចាំបាច់ក្នុងករណីនេះទេ ហើយថា សំណើនេះគួរត្រូវបានបដិសេធចោលទាំងស្រុងតែម្តង។ ប្រសិនបើអង្គជំនុំជម្រះសន្និដ្ឋានថា កាលៈទេសៈបច្ចុប្បន្ននេះនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ នួន ជា ក្នុងការទទួលបានសវនាការប្រកបដោយយុត្តិធម៌មែននោះ សហព្រះរាជអាជ្ញាសូមលើកឡើងថា ដំណោះស្រាយដែលសមរម្យគឺថា ក្នុងករណីដំបូង អង្គជំនុំជម្រះគួរចេញសេចក្តីសម្រេចជាលាយលក្ខណ៍មួយ ស្តីពីការជ្រើសរើសសាក្សី និងអ្នកជំនាញដែលបានស្នើឡើងដោយមេធាវីការពារក្តី ហើយនៅទីបញ្ចប់នៃការជំនុំជម្រះនៅដំណាក់កាលទីមួយ ផ្តល់ឱកាសឱ្យមេធាវីការពារក្តីដាក់សារណាជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ថាតើគួរមានការស្តាប់សាក្សីបន្ថែមទៀត ឬក៏មិនមាន សម្រាប់ឱ្យជនជាប់ចោទអនុវត្តសិទ្ធិនៃការជំនុំជម្រះក្តីដោយយុត្តិធម៌របស់គាត់។

# II. ប្រវត្តិនីតិវិធី

3. សំណើនេះកើតឡើងបន្ទាប់ពីមានប្រវត្តិដ៏វែងឆ្ងាយនៃការដាក់សារណាពីមេធាវីការពារក្តី ដោយគ្របដណ្តប់ទាំងនៅក្នុងកិច្ចដំណើរការនីតិវិធីមុនសវនាការ និងពេលសវនាការ។ ជាសង្ខេប សហព្រះរាជ

---

[1] ឯកសារ E212 សំណើសុំឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ ទាក់ទិននឹងការកោះហៅសាក្សីដែលបានស្នើឡើងដោយមេធាវីការពារក្តី (តទៅនេះហៅថា "សំណើ") ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១២ ("សំណើ")។

អាជ្ញាសូមពិនិត្យឡើងវិញតែសារណាមួយចំនួន ដែលពាក់ព័ន្ធបំផុតតែប៉ុណ្ណោះ។

4. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានបង្គាប់ឱ្យភាគីដាក់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្លួនស្នើឡើងសម្រាប់កិច្ចដំណើរការនីតិវិធីសវនាការ ក្នុងសំណុំរឿង ០០២[2] អនុលោមទៅតាមគំរូដែលបានផ្តល់ជូន[3] ("បញ្ជីដែលស្នើឡើងដោយភាគី")[4]។ ភាគីត្រូវបានតម្រូវឱ្យផ្តល់ដល់សាក្សីម្នាក់ៗ *ក្នុងចំណោមនោះ* នូវ "ការប៉ាន់ស្មាននូវរយៈពេលសម្រាប់ធ្វើសក្ខីកម្ម" "សេចក្តីសង្ខេបនៃអង្គហេតុដែលសាក្សីនឹងត្រូវផ្តល់សក្ខីកម្ម" ដែល "មានភាពលម្អិតគ្រប់គ្រាន់ដែលអាចឱ្យអង្គជំនុំជម្រះ និងភាគីអាចយល់បានពេញលេញនូវលក្ខណៈ និង ខ្លឹមសារនៃសក្ខីកម្មដែលបានស្នើសុំនោះ" និង "ចំណុចនៃការចោទប្រកាន់ដែលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញដែលបានស្នើសុំនោះរំពឹងថានឹងមកផ្តល់សក្ខីកម្ម ហើយត្រូវបញ្ជាក់ផងដែរនូវលេខកថាខណ្ឌនៃដីកាដំណោះស្រាយ និងបទចោទជាក់លាក់ណាមួយ"[5]។ អង្គជំនុំជម្រះបានទុកពេលឱ្យភាគីដាក់ជូននូវព័ត៌មាននេះរហូតដល់ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១[6]។

5. នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារក្តីបានស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាទៅលើសាក្សី ៥២៧ នាក់ អ្នកជំនាញ ១៣ នាក់ និង ដើមបណ្តឹងរដ្ឋប្បវេណី ៥ នាក់[7]។ តាមការប្រៀបធៀបឃើញថា សហព្រះរាជអាជ្ញាបានស្នើសាក្សី ២៤៧ នាក់ អ្នកជំនាញ ១៦ នាក់ និងដើមបណ្តឹងរដ្ឋប្បវេណី

---

2 ឯកសារ E9 ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ("ដីកា")។

3 ឯកសារ E9.2 បញ្ជីឈ្មោះសាក្សីដែលភាគីមានបំណងស្នើសុំឱ្យកោះហៅ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១; ឯកសារ E9.3 បញ្ជីឈ្មោះ ដើមបណ្តឹងរដ្ឋប្បវេណីដែលភាគីមានបំណងស្នើសុំឱ្យកោះហៅ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១; និង ឯកសារ E9.4 បញ្ជីឈ្មោះសាក្សីដែលភាគីមានបំណងស្នើសុំឱ្យកោះហៅ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១។

4 ឯកសារ E9 ដីកា លេខយោង ២ *ខាងលើ* ត្រង់កថាខណ្ឌ ៦។

5 ឯកសារ E9 ដីកា លេខយោង ២ *ខាងលើ* ត្រង់កថាខណ្ឌ ២, ៦។

6 ឯកសារ E9 ដីកា *ដូចខាងលើ*។

7 ឯកសារ E9/4/4.4 បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលភាគីមានបំណងស្នើសុំឱ្យកោះហៅ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១។

៣២ នាក់[8] ជនជាប់ចោទ ខៀវ សំផន បានស្នើសាក្សី ៣៥ នាក់ (*បន្ថែម*លើសាក្សីចំនួន ២៦ នាក់ដែលមានក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា) និងអ្នកជំនាញ ៣២ នាក់[9] ជនជាប់ចោទ អៀង សារី បានស្នើសាក្សី ៥ នាក់[10] និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសាក្សី ១៦ នាក់ អ្នកជំនាញ ១៥ នាក់ និងដើមបណ្តឹងរដ្ឋប្បវេណី ១៤០ នាក់[11] ដើម្បីឱ្យអង្គជំនុំជម្រះសាកសួរ។

6. ក្នុងចំណោមសាក្សី ៥២៧ នាក់ដែលបានស្នើដោយមេធាវីការពារក្តី យ៉ាងហោចក៏មានសាក្សី ១៣៤ នាក់ដែរ ដែលត្រូវបានកំណត់ថាពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រ។ សេចក្តីបរិយាយទាំងមូលដែលបានផ្តល់ដល់សាក្សីទាំងនោះមាន "ស្ថានភាពមុនឆ្នាំ ១៩៧៥" "ស្ថានភាពក្រោយឆ្នាំ ១៩៧៥" "ការពាក់ព័ន្ធរបស់សហរដ្ឋអាមេរិក" និង/ឬ "ការពាក់ព័ន្ធរបស់ស៊ីអាយអេ"។ បញ្ជីរបស់មេធាវីការពារក្តីរួមមានអ្នកការទូត ៧៣ នាក់ មន្ត្រីរដ្ឋាភិបាលបរទេស ៥៧ នាក់ បុគ្គលិកស្ថានទូត ១៩ នាក់ បុគ្គលិកអង្គការអន្តរជាតិ ៥៩ នាក់ សមាជិកគណបក្សនយោបាយបរទេស ១៥ នាក់ ប្រតិភូបរទេស ១១ នាក់ សាស្ត្រាចារ្យ ឬប្រវត្តិវិទូ ៣០ នាក់ និងអ្នកសារព័ត៌មាន ៥០ នាក់ ដែលអ្នកទាំងនេះភាគច្រើនត្រូវបានស្នើឱ្យផ្តល់សក្ខីកម្មពាក់ព័ន្ធតែទៅលើ "ស្ថានភាពមុនឆ្នាំ ១៩៧៥" នៅកម្ពុជា ឬការប្រព្រឹត្តិរបស់សហរដ្ឋអាមេរិកក្នុងអំឡុងពេលនោះតែប៉ុណ្ណោះ។

7. នៅថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ការជំទាស់បឋមទៅនឹងបញ្ជីឈ្មោះដែលបានស្នើឡើងដោយមេធាវីការពារក្តី ដែលមានឧបសម្ព័ន្ធចំនួន ១០ រៀបរាប់យ៉ាងពិស្តារអំពី

---

[8] ឯកសារ E9/4 បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១ ទី២ ទី ៣ ទី៣ក ទី៤ និងទី៥ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១។

[9] ឯកសារ E9/4/6 បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១។

[10] ឯកសារ E9/4/2 បញ្ជីស្នើឈ្មោះអ្នកជំនាញរបស់លោក អៀង សារី និងសេចក្តីជូនដំណឹងរបស់លោក អៀង សារី ទាក់ទងនឹងបញ្ជីឈ្មោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។

[11] ឯកសារ E9/8 សេចក្តីសង្ខេប និងគុណវុឌ្ឍិអ្នកជំនាញ ជាមួយនឹងចំណុចនៃការចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៨០ របស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងឧបសម្ព័ន្ធសម្ងាត់ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១។

ការជំទាស់ទៅនឹងសាក្សីជាក់លាក់ និងប្រភេទសាក្សី ("ការជំទាស់បឋម")[12]។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា បញ្ជីឈ្មោះសាក្សីដែលបានស្នើឡើងនោះខកខានមិនបានអនុវត្តតាមដីកាបង្គាប់របស់អង្គជំនុំជម្រះ តាមមធ្យោបាយបីយ៉ាង៖ (១) បញ្ជីឈ្មោះដែលបានស្នើឡើងពុំទាន់ជាបញ្ជីដាច់ស្រេចនៅឡើយ ប៉ុន្តែមេធាវីការពារបានផ្តល់បញ្ជីដែលមានឈ្មោះសាក្សីច្រើននាក់ ទាក់ទងនឹង "ប្រភេទដែលកើតមានផ្ទួនៗគ្នា" និងធ្វើឱ្យមាន "ការខកខានដោយគិតទុកជាមុន" ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងជាអ្នកធ្វើការជ្រើសរើស (២) ក្នុងករណីជាច្រើន សេចក្តីសង្ខេបមានកង្វះខាតនូវសេចក្តីពិស្តារគ្រប់គ្រាន់ស្តីពីលក្ខណៈនៃសក្ខីកម្មរបស់សាក្សីដែលបានស្នើឡើង ដើម្បីឱ្យភាគីដទៃទៀតយល់បាននូវទំនាក់ទំនងរវាងសក្ខីកម្ម និងបញ្ហានានាក្នុងពេលសវនាការ និង (៣) មេធាវីការពារក្តីមិនបានផ្តល់ការប៉ាន់ស្មាននូវពេលវេលាសម្រាប់សក្ខីកម្មរបស់សាក្សីដែលខ្លួនបានស្នើឡើងទេ[13]។ ជាងនេះទៀត ព័ត៌មានសម្រាប់ទាក់ទងដែលមេធាវីការពារក្តីផ្តល់ឱ្យសម្រាប់សាក្សីដែលបានស្នើឡើងសម្រាប់ផ្តល់សក្ខីកម្មស្តីពីស្ថានភាពមុនឆ្នាំ ១៩៧៥ គឺជាព័ត៌មានសម្រាប់ទាក់ទងដែលមានតាំងពីជាង ៣០ ឆ្នាំមុន ឬជាព័ត៌មានមិនពេញលេញ[14]។

8. សហព្រះរាជអាជ្ញាអន្តរជាតិក៏បានជំទាស់ផងដែរទៅនឹងសាក្សីមួយចំនួន ពីក្នុងបញ្ជីឈ្មោះសាក្សីដែលបានស្នើឡើងដោយមេធាវីការពារក្តីទាំងលើមូលដ្ឋានជាក់លាក់ និងប្រភេទសក្សី[15]។ ពាក់ព័ន្ធនឹងសាក្សីដែលមេធាវីការពារក្តីអះអាងថានឹងផ្តល់សក្ខីកម្មទាក់ទិននឹង "ស្ថានភាពមុនឆ្នាំ ១៩៧៥" នោះ សហព្រះរាជអាជ្ញាអន្តរជាតិបានកត់សម្គាល់ថា សេចក្តីសង្ខេបដែលបានផ្តល់ដោយមេធាវីការពារក្តីពី

---

12 ឯកសារ **E9/14/1/1** ការជំទាស់របស់សហព្រះរាជអាជ្ញា ទៅនឹងសាក្សី និងអ្នកជំនាញដែលបានស្នើឡើងដោយភាគីដទៃជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ចំនួន ១១ ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១១។

13 ឯកសារ **E9/14/1/1** ការជំទាស់បឋម *ដូចខាងលើ* ត្រង់កថាខណ្ឌ ១៣-១៧។

14 ឯកសារ **E9/4/4.4** ឧបសម្ព័ន្ធ ក៖ បញ្ជីឈ្មោះសាក្សី ដែលភាគីមានបំណងស្នើសុំឱ្យកោះហៅ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១។ ឧទាហរណ៍ ព័ត៌មានទំនាក់ទំនងដែលមេធាវីការពារក្តីបានផ្តល់សម្រាប់សាក្សីដែលបានបម្រើការងារឱ្យអង្គការ UNICEF នៅដើមទសវត្សរ៍ឆ្នាំ ១៩៧០ នៅទីក្រុងភ្នំពេញ គឺការិយាល័យអង្គការ UNICEF នៅទីក្រុងញូវយ៉កតែប៉ុណ្ណោះ។ ចំពោះសាក្សីដែលបម្រើការងារឱ្យរដ្ឋាភិបាលបរទេសផ្សេងទៀតនៅទីក្រុងភ្នំពេញកាលពីសម័យនោះ មេធាវីការពារក្តីគ្រាន់តែធ្វើបញ្ជីក្រសួងការបរទេសសម្រាប់ប្រទេសពួកគេតែប៉ុណ្ណោះ។

15 ឯកសារ **E9/14/1/1** ការជំទាស់បឋម *ដូចខាងលើ* ត្រង់កថាខណ្ឌ ១២។

សក្ខីកម្មសាក្សីដែលបានស្នើឡើងនោះ មានបំណងគូសបញ្ជាក់ថា សាក្សីនឹងផ្តល់ព័ត៌មានស៊ីជម្រៅនៅក្នុងស្ថានភាពមុនឆ្នាំ ១៩៧៥ តែ "មិនបានបញ្ជាក់ពីស្ថានភាពទាំងនោះ ឬពន្យល់ពីរបៀបដែលសក្ខីកម្មទាំងនេះជាប់ទាក់ទងនឹងដីការដំណោះស្រាយទេ"[16]។ ពាក់ព័ន្ធនឹងសាក្សីទាំងនោះដែលមេធាវីការពារក្តីបានអះអាងថានឹងផ្តល់សក្ខីកម្ម ទាក់ទិននឹងគោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិក និងប្រតិបត្តិការនៅប្រទេសកម្ពុជានោះ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានសង្កេតឃើញស្រដៀងគ្នាដែរថា "នួន ជា បានខកខានមិនបានបញ្ជាក់អំពីហេតុផលថា តើហេតុអ្វីបានជាស្នើសុំសាក្សីទាំងនេះ ឬអំពីចំណុចជាក់លាក់នានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលពួកគេនឹងត្រូវធ្វើការផ្តល់សក្ខីកម្ម"[17]។ សហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញកង្វល់ស្រដៀងគ្នាដែរ ទាក់ទិននឹងកង្វះខាតការបរិយាយពិស្តារស្តីពីសាក្សីដែលមេធាវីការពារក្តីបានអះអាងថា ពួកគេនឹងផ្តល់ព័ត៌មានទៅលើបញ្ហាប្រវត្តិសាស្ត្រ និងបរិបទដទៃទៀតនោះ[18]។

9. នៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១១ ដោយមានការពន្យារពេលក្នុងការពិចារណាទៅលើបញ្ជីដែលបានស្នើឡើងដោយមេធាវីការពារក្តី ដែលបានដាក់តែជាភាសាអង់គ្លេសនោះ សហព្រះរាជអាជ្ញាជាតិបានចូលរួមក្នុងការជំទាស់បឋម និងបានបន្ថែមការជំទាស់ទៅលើសាក្សី ៥ នាក់ទៀតដែលបានស្នើឡើងដោយមេធាវីការពារក្តី ដែលសាក្សីទាំងអស់មានតំណែងជាន់ខ្ពស់នៅក្នុងស្ថាប័ននីតិប្រតិបត្តិ ឬនីតិបញ្ញត្តិ នៃរាជរដ្ឋាភិបាលកម្ពុជា ("ការជំទាស់បន្ថែម")[19]។ ក្នុងន័យនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានសង្កេតឃើញថា ដោយយោងទៅលើរូបភាពជាក់ស្តែង ការតាំងសំណួរពីភាគីនានាតាមរយៈអង្គជំនុំជម្រះនោះជាទម្លាប់អនុវត្តដែលត្រូវបានអនុម័តដោយស្ថាប័នស៊ើបអង្កេត ឬតុលាការដទៃទៀតពាក់ព័ន្ធនឹងសាក្សីដែលជាចំណុចរសើប ដោយសារតែតួនាទី និងការទទួលខុសត្រូវបច្ចុប្បន្ន[20]។

---

16 ឯកសារ E9/14/1/1 ការជំទាស់បឋម *ដូចខាងលើ* ត្រង់កថាខណ្ឌ ២២។

17 ឯកសារ E9/14/1/1 ការជំទាស់បឋម *ដូចខាងលើ* ត្រង់កថាខណ្ឌ ២៤។

18 ឯកសារ E9/14/1/1 ការជំទាស់បឋម *ដូចខាងលើ* ត្រង់កថាខណ្ឌ ២៧-២៩។

19 ឯកសារ E9/14/1/1/1 ការជំទាស់បន្ថែម និងការកត់សម្គាល់របស់សហព្រះរាជអាជ្ញា ទៅនឹងសាក្សី និងអ្នកជំនាញដែលបានស្នើឡើងដោយភាគីដទៃ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១១។

20 ឯកសារ E9/14/1/1/1 ការជំទាស់បឋម *ដូចខាងលើ*។

10. នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញ *ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២*[21]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា បណ្តាសាក្សីដែលបានបញ្ចូលក្នុងបញ្ជីនេះពាក់ព័ន្ធតែនឹងអង្គហេតុចំនួន ៤ ដំបូង ដែលនឹងត្រូវយកមកពិចារណានៅពេលសវនាការ។ អង្គជំនុំជម្រះសាលាដំបូងក៏បានគូសបញ្ជាក់ផងដែរថា "អង្គជំនុំជម្រះនឹងជូនដំណឹងដល់ភាគីទាំងអស់នៅពេលក្រោយ អំពីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងចំណុចអង្គហេតុសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២ (ទាក់ទងនឹងការផ្លាស់ប្តូរទីលំនៅប្រជាជននៅដំណាក់កាលទីមួយ និងទីពីរ"[22]។

11. នៅថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ក្នុងពេលសវនាការផ្ទាល់មាត់ និងក្នុងការឆ្លើយតបទៅនឹងសំណើមួយពីមេធាវីការពារក្តីនោះ អង្គជំនុំជម្រះសាលាដំបូងបានអញ្ជើញមេធាវីការពារក្តីឱ្យដាក់បញ្ជីឈ្មោះសាក្សីបន្ថែមដែលខ្លួនយល់ថាពាក់ព័ន្ធនឹងដំណាក់កាលនៃសវនាការ ដែលកំពុងបន្តស្តីពីប្រវត្តិសាស្ត្រ[23]។ នៅថ្ងៃបន្ទាប់ មេធាវីការពារក្តីបានដាក់ជូនបញ្ជីឈ្មោះសាក្សី ៤៧ នាក់ ពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រដែលសាក្សីទាំងនោះជាផ្នែកមួយនៃបញ្ជីឈ្មោះសាក្សីបឋមរបស់មេធាវីការពារក្តី[24]។

12. នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់មេធាវីការពារក្តី ដោយគូសបញ្ជាក់ថា "សាក្សីទាំងនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងពិចារណានៅក្នុងការរៀបចំបញ្ជីឈ្មោះសាក្សីបណ្តោះអាសន្ន ... ហើយការដាក់បញ្ជីឈ្មោះសាក្សីមេធាវីការពារក្តី នួន ជា ... ពុំមានពន្យល់ហេតុផល ដែលអង្គជំនុំជម្រះគួរស្តាប់សក្ខីកម្មរបស់សាក្សីទាំង ៤៧ នាក់ភ្លាមៗឡើយ"[25]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះបានកត់សម្គាល់ថា សាក្សីទាំងអស់ដែលភាគីបានស្នើឡើងស្ថិតក្នុង

---

21 ឯកសារ **E131/1.1** ឧសម្ព័ន្ធសម្ងាត់ ក៖ ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ("បញ្ជីមួយផ្នែក")។

22 ឯកសារ **E131/1.1** បញ្ជីមួយផ្នែក *ដូចខាងលើ*។

23 ឯកសារ **E1/40.1** ប្រតិចារឹក ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ត្រង់ pp. 32 ln. 32-35 & 33 ln. 1-9។

24 ឯកសារ **E155/1.1** បញ្ជីឈ្មោះសាក្សីបន្ថែមដែលពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រ ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១២។

25 ឯកសារ **E172** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១២ ត្រង់ទំព័រ ៤។

ការពិចារណារបស់អង្គជំនុំជម្រះ រហូតដល់សាក្សីទាំងនេះត្រូវបានកោះហៅ ឬបដិសេធ និងថា នាពេលដ៏ខ្លីខាងមុខ អង្គជំនុំជម្រះនឹងចេញបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និង/ឬដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបដិសេធដំបូងគេ”[26]។

13. នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២ មេធាវីការពារក្តីបានដាក់បន្ថែមនូវ*សំណើសុំស្តាប់ចម្លើយសាក្សីដែលត្រូវបានស្នើដោយមេធាវីការពារក្តី និងចាត់ឱ្យមានវិធានការខាងនីតិវិធីផងទៀត ដើម្បីវាយតម្លៃឱ្យបានត្រឹមត្រូវលើបរិបទប្រវត្តិសាស្ត្រ*[27]។ សហព្រះរាជអាជ្ញាបានឆ្លើយតប នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ដោយលើកឡើងថា សំណើចុងក្រោយរបស់មេធាវីការពារក្តីនេះគឺគ្រាន់តែជាការដាក់ “បណ្តឹងដែលមានវិការៈ” សាជាថ្មីឡើងវិញប៉ុណ្ណោះ[28]។

## III. **ឧទ្ទិករណ៍**

### ក. **វិធាន ៨០ ស្ទួន ពុំតម្រូវឱ្យមានការស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់មេធាវីការពារក្តី ស្តីពីខ្លឹមសារនៃបញ្ជីដែលខ្លួនបានស្នើឡើងនោះឡើយ**

14. សំណើនេះភាគច្រើនផ្អែកលើការសន្មតថាវិធាន ៨០ ស្ទួន តម្រូវជាចាំបាច់ឱ្យមាន “ការលើកអំណះអំណាងផ្ទាល់មាត់គាំទ្រ និងប្រឆាំងនឹងការកោះហៅសាក្សី”[29]។ សំណើនេះយោងផ្ទួនៗទៅលើ “ភាសាដ៏សាមញ្ញ” នៃវិធាន ៨០ ស្ទួន[30]។ ក្នុងការគាំទ្រជំហរដែលថា សវនាការដោយផ្ទាល់មាត់ជាសាធារណៈ ស្តីពីបញ្ជីដែលមេធាវីការពារក្តីបានស្នើឡើង គឺជាលក្ខខណ្ឌគតិយុត្តមួយនៃវិធាន ៨០ ស្ទួន។ ក្នុងការប្រដូចលក្ខខណ្ឌដែលតម្រូវឱ្យអង្គជំនុំជម្រះធ្វើសវនាការដោយផ្ទាល់មាត់ជាសាធារណៈ

[26] ឯកសារ E172 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង *ដូចខាងលើ*។

[27] ឯកសារ E182 សំណើសុំស្តាប់ចម្លើយសាក្សីដែលត្រូវបានស្នើដោយមេធាវីការពារក្តី និងចាត់ឱ្យមានវិធានការខាងនីតិវិធីផងទៀត ដើម្បីវាយតម្លៃឱ្យបានត្រឹមត្រូវលើបរិបទប្រវត្តិសាស្ត្រ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២។

[28] ឯកសារ E182/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង “សំណើរបស់ នួន ជា សុំស្តាប់ចម្លើយសាក្សីដែលបានស្នើដោយមេធាវីការពារក្តី និងចាត់វិធានការខាងនីតិវិធីផ្សេងទៀត ដើម្បីវាយតម្លៃឱ្យបានត្រឹមលើបរិបទប្រវត្តិសាស្ត្រ” ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២។

[29] ឯកសារ E212 សំណើ លេខសម្គាល់ ១ *ខាងលើ* ត្រង់កថាខណ្ឌ ១៥។

[30] *ដូចខាងលើ* ត្រង់កថាខណ្ឌ ១៤ និង១៥។

00827251

E212/1



ស្តីពីបុគ្គលដែលអាចធ្វើជាសាក្សី និងអ្នកជំនាញ ជាមួយនឹងលក្ខខណ្ឌដែលតម្រូវឲ្យយអង្គជំនុំជម្រះពិចារណាលើសេចក្តីសន្និដ្ឋានរបស់ភាគីទាំងអស់ស្តីពី សាក្សីនានា ដែលភាគីនីមួយៗបានស្នើសុំកោះហៅ មេធាវីការពារក្តីអះអាងថា អង្គជំនុំជម្រះ "ល្មើសនឹងកាតព្វកិច្ចរបស់ខ្លួន" ចំពោះការមិនស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ខ្លួន ពាក់ព័ន្ធទៅនឹងបុគ្គលដែលអាចធ្វើជាសាក្សី នៅក្នុងបញ្ជីដែលខ្លួនបានស្នើឡើង ដើម្បីវាយតម្លៃថាតើត្រូវកោះហៅសាក្សីទាំងនេះនៅសវនាការដែរ ឬយ៉ាងណា[31]។

15. សហព្រះរាជអាជ្ញាសូមលើកឡើងថាទស្សនៈខាងលើ គឺផ្អែកលើការបកស្រាយពុំត្រឹមត្រូវអំពីនីតិវិធីដែលវិធាន ៨០ ស្ទួនបានបង្គាប់។ វិធាននេះចែងថា នៅក្នុងពេលសវនាការបឋម អង្គជំនុំជម្រះ "ត្រូវពិចារណាអំពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញដែលដាក់ជូនដោយភាគី" ដែលត្រូវតែធ្វើជា "ចំហ"[32]។ នៅពេលអង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថាការស្តាប់សាក្សី ឬអ្នកជំនាញដែលត្រូវបានស្នើសុំកោះហៅនឹងមិននាំមកនូវដំណើរការល្អនៃការស្វែងរកយុត្តិធម៌ អង្គជំនុំជម្រះសាលាដំបូងត្រូវបដិសេធសំណើសុំឲ្យកោះហៅបុគ្គលនោះ[33]។

16. សហព្រះរាជអាជ្ញាសម្គាល់ឃើញថា វិធាន ៨០ ពុំចែងលម្អិតអំពីខ្លឹមសារ ឬសណ្ឋាននៃការពិចារណារបស់អង្គជំនុំជម្រះអំពីបញ្ជីដែលភាគីបានស្នើឡើងឡើយ។ លក្ខខណ្ឌដែលតម្រូវថា អង្គជំនុំជម្រះត្រូវពិចារណាអំពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញដែលភាគីបានស្នើឡើង នៅសវនាការបឋមពុំមានបរិយាយអំពីការលើកអំណះអំណាងផ្ទាល់មាត់ឡើយ។ ជាការពិត មេធាវីការពារក្តីបានទទួលស្គាល់ភាពពុំច្បាស់លាស់ទាំងនេះនៅក្នុងសំណើផ្ទាល់មាត់ស្នើសុំ "ការណែនាំ" អំពីអត្ថន័យនៃពាក្យ "ពិចារណា" ក្នុងវិធាន ៨០[34]។

17. សហព្រះរាជអាជ្ញាសូមអះអាងថា ការបកស្រាយដ៏ត្រឹមត្រូវនៃវិធាន ៨០ ស្ទួន ដោយយោងទៅលើការ

---

31 *ដូចខាងលើ* ត្រង់កថាខណ្ឌ ១៤។

32 វិធាន ៨០*ស្ទួន*។

33 *ដូចខាងលើ*។

34 ឯកសារ E1/7.1 ប្រតិចារឹកនៃសវនាការបឋម៖ នួន ជា, អៀង សារី, អៀង ធីរិទ្ធ, ខៀវ សំផន ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ត្រង់ទំព័រ៣៧ បន្ទាត់១៥-១៧ ("ប្រតិចារឹកថ្ងៃទី២")។

ទទួលខុសត្រូវរបស់អង្គជំនុំជម្រះក្នុងការរៀបចំសវនាការ[35] ផ្តល់ឆន្ទានុសិទ្ធិទូលំទូលាយ ដើម្បីកំហិតលក្ខណៈ និងវិសាលភាពនៃការពិចារណាអំពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ នៅសវនាការបឋម។

18. វិសាលភាពនៃឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ អាចត្រូវបានបញ្ជាក់បំភ្លឺតាមការពិនិត្យទៅលើវិធានផ្សេងៗ ដែលផ្តល់បរិបទចាំបាច់សម្រាប់ការបកស្រាយត្រឹមត្រូវអំពីវិធាន ៨០ ស្ទួន។ ខុសពីវិធាន ៨០ ស្ទួន វិធានដទៃទៀតចែងច្បាស់អំពីសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ភាគី ឬរវាងភាគី។ ជាឧទាហរណ៍ វិធាន ៧៩ (៧) ពាក់ព័ន្ធនឹងកិច្ចប្រជុំរៀបចំសវនាកាជាផ្លូវការចែងថា "គោលបំណងនៃការប្រជុំនឹងអនុញ្ញាតឱ្យមានការផ្លាស់ប្តូរយោបល់រវាងភាគីទាំងឡាយ ដើម្បីសម្របសម្រួលការកំណត់កាលបរិច្ឆេទនៃការធ្វើសវនាការបឋម សវនាការលើអង្គសេចក្តី"[36]។ ពាក់ព័ន្ធនឹងសក្ខីកម្មសាក្សី វិធាន ៩១ ចែងថា "សហព្រះរាជអាជ្ញា ភាគីទាំងអស់ និងមេធាវីត្រូវបានអនុញ្ញាតឱ្យសួរសំណួរ ដោយមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះសាលាដំបូង"[37] ហើយ "សហព្រះរាជអាជ្ញា និងភាគីដទៃទៀត និងមេធាវីអាចជំទាស់ទៅនឹងការស្តាប់ចម្លើយសាក្សីដែលកំពុងដំណើរការ [...]"[38]។ ស្រដៀងនេះ វិធាន ៨៩ ស្ទួន ចែងច្បាស់ថា មុនពេលនៃការសួរសំណួរទៅជនជាប់ចោទណាម្នាក់ សហព្រះរាជអាជ្ញាអាច "ធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់សង្ខេប" ដែលជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទអាចឆ្លើយតប[39]។ ដូច្នេះ ក្នុងក្របខ័ណ្ឌនៃវិធានផ្ទៃក្នុង ការមិនមានចែងនៅក្នុងវិធាន ៨០ស្ទួន អំពីការលើកអំណះអំណាងដោយផ្ទាល់មាត់ បង្ហាញថា ការចូលរួមតាមរយៈសេចក្តីសន្និដ្ឋានដោយផ្ទាល់ មាត់ពុំមែនជាការចាំបាច់ឡើយ ហើយយ៉ាងហោចណាស់ស្ថិតក្នុងរង្វង់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ។

19. វិធាន ៨០ ផ្តល់សិទ្ធិអំណាចឆន្ទានុសិទ្ធិដល់អង្គជំនុំជម្រះ ដើម្បីបង្គាប់ឱ្យភាគីដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធនឹងបញ្ជីឈ្មោះសាក្សីដែលភាគីបានស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅដែលជាសេចក្តីសង្ខេប "លម្អិត" សមល្មមដើម្បី "អនុញ្ញាតឱ្យអង្គជំនុំជម្រះ និងភាគីផ្សេងៗយល់

---

[35] សូមមើល កថាខណ្ឌ ២៤ ខាងក្រោម។

[36] វិធាន ៧៩ (៧)។

[37] វិធាន ៩១ (២)។

[38] វិធាន ៩១ (៣)។

[39] វិធាន ៨៩*ស្ទួន*។

ពេញលេញអំពីលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្មដែលភាគីបានស្នើសុំ"[40]។ បញ្ជីដែលភាគីបានស្នើឡើងត្រូវបានដាក់នៅមុនពេលសវនាការបឋម ដោយអនុលោមតាមវិធាន ៨០ ស្ទួន។ ដោយយោងទៅលើការរំពឹងអំពីសេចក្តីលម្អិតនៅក្នុងសេចក្តីសន្និដ្ឋានទាំងនេះ ដែលមេធាវីការពារក្តីខកខានផ្ទួនៗ ក្នុងការគោរពតាម[41]។ ការកំណត់វិសាលភាពសមស្របនៃ "ការពិចារណា" របស់ខ្លួនអំពីបុគ្គលដែលអាចធ្វើសាក្សី និងអ្នកជំនាញនៅសវនាការបឋម ស្ថិតក្រោមឆន្ទានុសិទ្ធិនៃការរៀបចំសវនាការរបស់អង្គជំនុំជម្រះ។ ក្នុងសំណុំរឿងនេះ អង្គជំនុំជម្រះបានស្នើឱ្យភាគីដាក់ចូលទៅក្នុងបញ្ជី "តាមលំដាប់លំដោយនៃភាពពាក់ព័ន្ធ និងតម្លៃជាភស្តុតាង"នូវសាក្សីថ្មីៗដែលភាគីបានស្នើសុំកោះហៅដែល "ពាក់ព័ន្ធបំផុតទៅនឹងចំណុចអង្គហេតុទាំង៤ ដែលត្រូវធ្វើសវនាការដំណាក់កាលទី១" និងបានស្នើឱ្យភាគីផ្តល់ "ហេតុផលចំពោះការដាក់បញ្ចូលឈ្មោះពួកគាត់នៅក្នុងអាទិភាពដូចដែលបញ្ជាក់"[42]។ វត្តមាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរស្តីពីបញ្ជីដែលភាគីបានស្នើឡើង កំហិតភាពចាំបាច់នៃការលើកអំណះអំណាងផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះ ដែលបានទទួលសំណើរបស់ភាគីរួចហើយ។

20. ភាពបត់បែនដែលត្រូវបានបង្កើតឡើងនៅក្នុងវិធាន ៨០ ស្ទួន បង្ហាញថាអង្គជំនុំជម្រះនៅមានឆន្ទានុសិទ្ធិដើម្បីស្វែងរកមធ្យោបាយមួយក្នុងចំណោមមធ្យោបាយមួយចំនួននៃ "ការពិចារណា" ជាសាធារណៈអំពីបញ្ជីដែលភាគីបានស្នើឡើងនៅសវនាការបឋម

(i) ផ្តល់សេចក្តីសន្និដ្ឋានបណ្តោះអាសន្នរបស់ខ្លួនស្តីពីបញ្ជីដែលភាគីបានស្នើឡើង

(ii) បង្ហាញបញ្ជីបណ្តោះអាសន្នរបស់ខ្លួនទៅភាគី និងស្នើសុំសេចក្តីសន្និដ្ឋានផ្ទាល់មាត់

(iii) អនុញ្ញាតឱ្យភាគីធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ ពាក់ព័ន្ធនឹងបញ្ជីបណ្តោះអាសន្នរបស់អង្គជំនុំជម្រះ និងបញ្ជីដែលភាគីបានស្នើឡើង។ ក្នុងសំណុំរឿងនេះ អង្គជំនុំជម្រះបានប្រកាន់យកផ្លូវកណ្តាល ដោយធ្វើ

---

[40] វិធាន ៨០ (៣)។

[41] ឯកសារ **E9/14/1/1** ការជំទាស់បឋម លេខសម្គាល់ ១២ *ខាងលើ* ត្រង់កថាខណ្ឌ ១២-៣៨; ឯកសារ **E182/1** ចម្លើយតបទៅនឹងសាក្សីបន្ថែមរបស់មេធាវីការពារក្តី លេខសម្គាល់ ២៨ *ខាងលើ* ត្រង់កថាខណ្ឌ ១០-១១។

[42] ឯកសារ **E93** សេចក្តីណែនាំនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ ("តទៅនេះហៅថា "សេចក្តីណែនាំ") ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១១ ត្រង់ទំព័រ ២។

ការជូនដំណឹងទៅភាគីអំពីបញ្ជីបណ្តោះអាសន្នរបស់ខ្លួន និងការស្តាប់យោបល់របស់ភាគីស្តីពីការសម្រេចរបស់អង្គជំនុំជម្រះ[43]។ សហព្រះរាជអាជ្ញា សង្កេតឃើញថា អង្គជំនុំជម្រះបានយកចិត្តទុកដាក់ជូនដំណឹងទៅភាគីអំពីលទ្ធផលដ៏សំខាន់នេះនៅកិច្ចប្រជុំរៀបចំសវនាការមួយ មុនពេលសវនាការបឋម៖

> *អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចសង្ខេបពាក់ព័ន្ធនឹងបញ្ហារដ្ឋបាលតុលាការ រួមទាំងពេលវេលាកំណត់សម្រាប់ចម្លើយតប និង<u>ថាតើការលើកអំណះអំណាង ឬចម្លើយតបផ្ទាល់មាត់ មានភាពចាំបាច់ដែរ ឬយ៉ាងណា</u>*[44]

21. ថ្វីបើអង្គជំនុំជម្រះពុំបានផ្តល់ឱកាសទៅភាគី ដើម្បីធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ ស្តីពីបុគ្គលនានាដែលត្រូវលុបឈ្មោះពីបញ្ជីបណ្តោះអាសន្នរបស់ខ្លួន លទ្ធភាពនៅមាន៖ "ប្រសិនបើសវនាការជាសាធារណៈណាមួយសម្រាប់ការលើកអំណះអំណាងដោយផ្ទាល់មាត់មានភាពចាំបាច់ សវនាការទាំងនោះ នឹងត្រូវប្រកាសដោយជូនដំណឹងច្រើនតាមតែអាចធ្វើបាន"[45]។ ដោយស្នើភាគីធ្វើសេចក្តីសន្និដ្ឋានបន្ថែមពាក់ព័ន្ធនឹងសាក្សី ដែលពាក់ព័ន្ធជាក់លាក់ទៅនឹងចំណុចអង្គហេតុដែលត្រូវធ្វើសវនាការនៅដំណាក់កាលដំបូង[46] អង្គជំនុំជម្រះបានគូសបញ្ជាក់ថា នៅពេលសំណុំរឿងនេះដំណើរការ ខ្លួននឹងផ្តល់ព័ត៌មានបន្ថែមអំពីការទទួលយក ឬការបដិសេធរបស់ខ្លួនចំពោះសាក្សីដែលពុំមានឈ្មោះក្នុងបញ្ជីបណ្តោះអាសន្ននេះ[47]។ ដោយហេតុថា អង្គជំនុំជម្រះធ្លាប់បានអនុញ្ញាតឱ្យមានការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់លើអង្គសេចក្តី និងបានអនុញ្ញាតឱ្យមានសារណាជាលាយលក្ខណ៍អក្សរស្តីពីសាក្សីនានាដែលមានឈ្មោះក្នុងបញ្ជីមកទល់នឹងពេលបច្ចុប្បន្ន ការសម្រេចរបស់ខ្លួនស្ថិតក្រោមឆន្ទានុសិទ្ធិដែលបានផ្តល់ដោយវិធាន ៨០ ស្ទួន។

## ខ. សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស ពុំតម្រូវឱ្យមានការស្តាប់អំណះអំណាងផ្ទាល់មាត់របស់មេធាវីការពារក្តីស្តីពីខ្លឹមសារនៃបញ្ជីដែលខ្លួនបានស្នើឡើងឡើយ

---

[43] ឯកសារ **E1/7.1** ប្រតិចារឹកថ្ងៃទី២ លេខសម្គាល់ ៣៤ *ខាងលើ* ត្រង់ទំព័រ២ បន្ទាត់៧-៩។

[44] ឯកសារ **E1/2.1** ប្រតិចារឹក៖ កិច្ចប្រជុំរៀបចំសវនាការ (តទៅនេះហៅថា "ប្រតិចារឹកកិច្ចប្រជុំ") ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ត្រង់ទំព័រ៨ បន្ទាត់ ១៩-២២ [គូសបញ្ជាក់បន្ថែម]។

[45] ឯកសារ **E1/7.1** ប្រតិចារឹកថ្ងៃទី២ លេខសម្គាល់ ៣៤ *ខាងលើ* ត្រង់ទំព័រ៤៨ បន្ទាត់១១-១៣។

[46] *សូមមើលឧទាហរណ៍* ឯកសារ **E1/7.1** ប្រតិចារឹកថ្ងៃទី២ *ដូចខាងលើ* ត្រង់ទំព័រ២ បន្ទាត់១៣-២១។

[47] ឯកសារ **E172** អនុស្សរណៈ៖ លេខសម្គាល់ ២៥ ត្រង់ទំព័រ៤។

22. សហព្រះរាជអាជ្ញាសូមអះអាងថាទម្លាប់អនុវត្តន៍របស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងបញ្ជី ដែលមេធាវីការពារក្តី បានស្នើឡើង គឺស្របជាមួយសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័សគោលការណ៍ជាសារវ័ន្ត ដែលមានចែងនៅក្នុងវិធាន ២១ និងទម្លាប់អនុវត្តជាក់លាក់របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀត ពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សី។

23. មួយផ្នែកនៃវិធាន ២១ ចែងថា កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក "ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"[48] ហើយការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះត្រូវធ្វើការជំនុំជម្រះ ក្នុងរយៈពេលមួយសមស្រប"[49]។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការលើសំណុំរឿង ០០២ អង្គជំនុំជម្រះបានគូសបញ្ជាក់ថា៖

> ភាពស្មុគស្មាញនៃការជំនុំជម្រះទាំងនេះ ទាមទារភាពបត់បែននៃនីតិវិធីក្នុងកម្រិតមួយ ដូច្នេះទើបអង្គជំនុំជម្រះនឹងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀង អ.វ.ត.ក, ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, និងវិធានផ្ទៃក្នុង ដើម្បីបង្កើតឡើងនូវនីតិវិធីជំនុំជម្រះដែលចាំបាច់ដើម្បីធានាបាននូវកិច្ចដំណើរការនីតិវិធីមួយ ប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស[50]។

ក្នុងសេចក្តីណែនាំមុនពេលសវនាការបឋម អង្គជំនុំជម្រះកត់សម្គាល់ទៀតថា "ដោយហេតុថា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស ទើបមានភាពចាំបាច់ដែលត្រូវកាត់បន្ថយចំនួនសាក្សី ដែលត្រូវកោះហៅនៅសវនាការ"[51]។ កាលៈទេសៈនៃសំណុំរឿង ០០២ ខុសប្លែកពីសំណុំរឿង ០០១។ គិតត្រឹមពេលសវនាការបឋមលើសំណុំរឿង ០០១ ដែលអំឡុងពេលនោះអង្គជំនុំជម្រះបានអនុញ្ញាតឱ្យភាគីលើកអំណះអំណាងផ្ទាល់មាត់ ស្តីពីបញ្ជីឈ្មោះសាក្សីរបស់ខ្លួន មេធាវីការពារក្តីបានស្នើសុំកោះហៅសាក្សីចំនួនសរុប ១៣ នាក់[52]។ ប៉ុន្តែ គិតមកទល់នឹងពេលសវនាការបឋមលើសំណុំរឿង ០០២ វិញ មេធាវីការពារក្តី នួន ជា តែមួយក្រុមប៉ុណ្ណោះ បានស្នើសុំ

---

[48] វិធាន ២១ (១)។

[49] វិធាន ២១ (៤)។

[50] ឯកសារ E1/2.1 ប្រតិចារឹកកិច្ចប្រជុំ, *យោងខាងលើ*កំណត់សម្គាល់លេខ៤៤ ត្រង់ទំព័រ៨ បន្ទាត់១២-១៧។

[51] ឯកសារ E93 សេចក្តីណែនាំ លេខសម្គាល់ ៤២ *ខាងលើ* ត្រង់ទំព័រ១។

[52] ឯកសារ E1/3.1 ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី៖ សវនាការបឋមលោករឿងក្តី "ឌុច"ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ត្រង់ទំព័រ១០៤ បន្ទាត់៦។

កោះហៅសាក្សីចំនួនសរុប ៥២៧ នាក់[53] ដែលចំនួនសរុបត្រួតគ្នានៃអ្នកជំនាញ និងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីកើនឡើងដល់ ១០៥៤ នាក់ ដែលជាចំនួនមួយមិនអាចធ្វើការកោះហៅបាន[54]។ ជំហររបស់សហព្រះរាជអាជ្ញាជាហូរហែរ គឺគាំទ្រកិច្ចដំណើរការនីតិវិធីជាសាធារណៈ ប៉ុន្តែក្នុងឋានៈជា "អ្នកគ្រប់គ្រងសំណុំរឿង" អង្គជំនុំជម្រះត្រូវពិនិត្យលើការជ្រើសរើសសាក្សី នៅពេលដែលខ្លួនយល់ថាសមស្រប[55]។ ដោយពិចារណាលើកត្តាទាំងអស់នេះ យើងឃើញថា អង្គជំនុំជម្រះបានបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយអនុលោមតាមវិធាន ២១ ក្នុងការសម្រេចថា ការអនុញ្ញាតឱ្យមានការលើកអំណះអំណាងដោយផ្ទាល់មាត់ ពាក់ព័ន្ធនឹងបុគ្គលម្នាក់ៗក្នុងចំណោមបុគ្គលចំនួន ១០៥៤ នាក់ ដែលភាគីបានស្នើសុំកោះហៅ (ឬបុគ្គលចំនួន ៥២៧ នាក់ដែលមេធាវីការពារក្តីស្នើសុំកោះហៅ) នឹងពុំអំណោយផលដល់ការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័សឡើយ។

24. ការសម្រេចនេះគឺអនុវត្តតាមមាគ៌ាយុត្តិសាស្ត្រមួយរបស់តុលាការ ICTY និងតុលាការ ICTR ដែលផ្តល់អំណាចឆន្ទានុសិទ្ធិទូលំទូលាយដល់អង្គជំនុំជម្រះ ក្នុងការអនុវត្តការទទួលខុសត្រូវលើការរៀបចំសវនាការចំពោះសក្ខីកម្មរបស់សាក្សី។ នៅក្នុងសំណុំរឿងរដ្ឋអាជ្ញា ទល់នឹង *Ndayambaje et al.* អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICTR បានវាយតម្លៃថាតើអង្គជំនុំជម្រះសាលាដំបូងបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ពាក់ព័ន្ធនឹងនីតិវិធីដែលត្រូវបានអនុវត្ត ដើម្បីកាត់បន្ថយចំនួនសាក្សីដែរ ឬទេ និងបានសំអាងទៅលើ "ការស៊ាំជាមួយសកម្មភាពប្រចាំថ្ងៃរបស់ភាគី និងតម្រូវការជាក់ស្តែងនៃសំណុំរឿងនេះ"[56]។ យោងតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការកាត់បន្ថយបញ្ជីឈ្មោះសាក្សី អង្គជំនុំជម្រះតុលាការឧទ្ធរណ៍បានកត់សម្គាល់ទៀតថា "ភារកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បី

[53] ឯកសារ **E212** សំណើ លេខសម្គាល់ ១ *ខាងលើ* ត្រង់កថាខណ្ឌ ១៩។

[54] ឯកសារ **E1/4.1** ប្រតិចារឹកនៃសវនាការបឋម៖ នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ត្រង់ទំព័រ២៣ បន្ទាត់១៩។

[55] ឯកសារ **E1/7.1** ប្រតិចារឹកថ្ងៃទី២ លេខសម្គាល់ ៣៤ *ខាងលើ* ត្រង់ទំព័រ១៦-១៧ បន្ទាត់២២-២។

[56] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Elie Ndayambaje និងអ្នកដទៃទៀត* សំណុំរឿង ICTR-98-42-AR73, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Joseph Kanyabashi ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង II ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៧ ដែលពាក់ព័ន្ធនឹងការបដិសេធសំណើសុំផ្លាស់ប្តូរបញ្ជីឈ្មោះសាក្សីរបស់ខ្លួន (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR) ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៧ ត្រង់កថាខណ្ឌ ១០។

ធានាបានថាភាពត្រឹមត្រូវ និងឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ត្រូវមានការរក្សាតុល្យភាពនៃផលប្រយោជន៍ភាគី"[57] ដែលនេះជាសេចក្តីបញ្ជាក់មួយដែលពាក់ព័ន្ធនឹងសំណុំរឿងបច្ចុប្បន្ន។ ក្នុងសំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង* *Karemera et al.*, តុលាការ ICTR បានអះអាងជាថ្មីដោយគាំទ្រនូវអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងផ្នែករដ្ឋបាលតុលាការដោយបានលើកឡើងថាអង្គជំនុំជម្រះជា "សមត្ថកិច្ចមួយដែលមានភារៈដោះស្រាយ បញ្ហានានាពាក់ព័ន្ធការរៀបចំសវនាការបានល្អ"[58]។ តុលាការ ICTY បានអនុម័តវិធាននីតិវិធីស្រដៀងនេះដែរ។ ក្នុងសំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង* *Milutinovic et al.*, សេចក្តីសម្រេចពាក់ព័ន្ធនឹងការពុំដាក់បញ្ចូលសាក្សីទៅក្នុងកិច្ចដំណើរការជំនុំជម្រះ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍បានថែងថា "មានការបញ្ជាក់ច្បាស់នៅក្នុងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិថា អង្គជំនុំជម្រះសាលាដំបូងអនុវត្តឆន្ទានុសិទ្ធិក្នុងប្រភេទផ្សេងៗនៃសេចក្តីសម្រេចសម្រាប់គោលបំណងនៃការរៀបចំសវនាការប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស..."[59]។

25. ផ្អែកតាមមូលដ្ឋាននេះ សហព្រះរាជអាជ្ញាសូមអះអាងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីកំហិតវិសាលភាពនៃការលើកអំណះអំណាងផ្ទាល់មាត់នៅឯសវនាការបឋម មកនៅត្រឹមបញ្ជីឈ្មោះសាក្សីបណ្តោះអាសន្នរបស់ខ្លួនវិញ គឺជាការអនុវត្តត្រឹមត្រូវនៃឆន្ទានុសិទ្ធិនៃការរៀបចំសវនាការ។ អំណះអំណាងរបស់មេធាវីការពារក្តីដែលថា ការអនុវត្តឆន្ទានុសិទ្ធិនេះគឺជាការបំពានលើវិធាន ៨០ *ស្ទួន* និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវតែពុំមានសុពលភាព។

### គ. គោលការណ៍នៃសមភាពក្នុងការតទល់គ្នាក្នុងរឿងក្តី ពុំតម្រូវឱ្យមានសវនាការសម្រាប់ឱ្យក្រុមមេធាវីការពារក្តីធ្វើសន្និដ្ឋានដោយផ្ទាល់មាត់អំពីខ្លឹមសារនៃបញ្ជីឈ្មោះដែលបានស្នើសុំនោះទេ

---

[57] *ដូចខាងលើ* ត្រង់កថាខណ្ឌ ២៤។

[58] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Edouard Karemera* *និងអ្នកដទៃទៀត* សំណុំរឿង ICTR-98-44-T, សេចក្តីសម្រេចលើសំណើរបស់ Joseph Nzirorera សុំពន្យារពេល ឬបង្ខិតបង្ខំឱ្យ Casimir Bizimungu មកផ្តល់សក្ខីកម្មអង្គជំនុំជម្រះសាលាដំបូង ICTR III ថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០១០ ត្រង់កថាខណ្ឌ ៤។

[59] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Milan Milutinovic* *និងអ្នកដទៃទៀត* សំណុំរឿង IT-05-87-AR73.1, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ដែលបដិសេធមិនឱ្យរដ្ឋអាជ្ញាបន្ថែមឧត្តមសេនីយ៍ Wesley Clark ទៅក្នុងបញ្ជីរបស់ខ្លួន អនុលោមតាមវិធាន ៦៥*ស្ទួនពីរ* ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៧ ត្រង់កថាខណ្ឌ ៨។

26. អង្គជំនុំជម្រះបានទទួលស្គាល់ថា ចរិតលក្ខណៈជាមូលដ្ឋាននៃគោលការណ៍នៃសមភាពក្នុងការតទល់គ្នាក្នុងរឿងក្ដីត្រូវបានទទួលស្គាល់នៅក្នុងវិធានផ្ទៃក្នុង[60]។ អង្គជំនុំជម្រះតុលាការកំពូលនៃបណ្ដាសាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិនានាបានទទួលស្គាល់ និងកំណត់វិសាលភាពនៃការអនុវត្តគោលការណ៍នៃសមភាពក្នុងការតទល់គ្នាក្នុងរឿងក្ដី[61]។ នៅក្នុងចង្កោមយុត្តិសាស្ត្រទាំងនេះ សមភាពក្នុងការតទល់គ្នាក្នុងរឿងក្ដីត្រូវបានកំណត់និយមន័យថា "ភាគីនីមួយៗត្រូវមានឱកាសសមស្រប សម្រាប់បង្ហាញរឿងក្ដីរបស់ខ្លួនក្រោមលក្ខខណ្ឌដែលពុំធ្វើឱ្យខូចប្រយោជន៍ធំធេង *ដល់* គូបដិបក្ខរបស់ខ្លួន"[62] ហើយ "ការជំនុំជម្រះដោយយុត្តិធម៌ត្រូវផ្ដល់សិទ្ធិឱ្យជនជាប់ចោទមានពេលវេលា និងសម្ភារៈគ្រប់គ្រាន់សម្រាប់ការការពារក្ដីរបស់ខ្លួន"[63]។

27. ទោះបីជាសហព្រះរាជអាជ្ញាទទួលស្គាល់ថា គោលការណ៍នៃសមភាពក្នុងការតទល់គ្នាក្នុងរឿងក្ដី គឺជាយន្តការធានាដ៏សំខាន់មួយ ចំពោះសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្ដីប្រកបដោយភាពយុត្តិធម៌របស់ជនជាប់ចោទក៏ដោយ ក៏សហព្រះរាជអាជ្ញាសូមសន្និដ្ឋានថា សំណើសុំនេះបកស្រាយមិនត្រឹមត្រូវលើវិសាលភាពនៃការអនុវត្តគោលការណ៍នេះ ហើយជាពិសេសនោះ លើពាក្យ "ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់" ដើម្បីធ្វើការការពារខ្លួន ដោយបែរជាសំដៅលើការប្រព្រឹត្តិដូចគ្នានៅក្នុងបញ្ហានីតិវិធី និងបញ្ហាសារធាតុទាំងឡាយទៅវិញ។ យុត្តិសាស្ត្រអន្តរជាតិចែងយ៉ាងច្បាស់ថា "សិទ្ធិ

---

[60] ឯកសារលេខ **D288/6.90** សេចក្ដីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់អំណះអំណាងឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៩ ត្រង់កថាខណ្ឌ ៥។

[61] *សូមមើល ឧ. រដ្ឋអាជ្ញា ទល់នឹង Duško Tadić* រឿងក្ដីលេខ Case No. IT-94-1-A សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ ត្រង់កថាខណ្ឌ ៤៤។ *រដ្ឋអាជ្ញា ទល់នឹង Clément Kayishema* និង *Obed Ruzindana* រឿងក្ដីលេខ ICTR-95-1-T សាលដីកា (សំអាងហេតុ) (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR) ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០១ ត្រង់កថាខណ្ឌ ៦៧។ *រដ្ឋអាជ្ញា ទល់នឹង Charles Ghankay Taylor* រឿងក្ដីលេខ SCSL-03-01-T សេចក្ដីសម្រេចលើសេចក្ដីជូនដំណឹងនៃការដាក់បណ្ដឹងសាទុក្ខ និងសេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹង សេចក្ដីសម្រេចដោយផ្ទាល់មាត់នាថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០០៩ ដែលតម្រូវឱ្យក្រុមមេធាវីការពារក្ដីចាប់ផ្ដើមរឿងក្ដី របស់ខ្លួននៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ (អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL) ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ ត្រង់កថាខណ្ឌ ១៦។

[62] រឿងក្ដី Taylor *ដូចខាងលើ* កថាខណ្ឌ ១៧។

[63] រឿងក្ដី *Tadić* លេខកំណត់សម្គាល់ ៦១ *ខាងលើ* ត្រង់កថាខណ្ឌ ៤៧។

របស់ជនជាប់ចោទ និងសមភាពរវាងភាគី ពុំគួរ [...] យល់ច្រឡំជាមួយនឹងលក្ខខណ្ឌតម្រូវឱ្យមានភាពស្មើគ្នាជាក់លាក់នៃមធ្យោបាយ ធនធាន និងពេលវេលានោះទេ"។ គោលការណ៍នៃសមភាពក្នុងការតទល់គ្នាក្នុងរឿងក្តី ត្រូវបានបង្កើតឡើងដើម្បីផ្តល់សិទ្ធិ និងផ្តល់ការធានាជាលក្ខណៈនីតិវិធីដល់ភាគីនៃរឿងក្តី"[64]។

28. ការអះអាងរបស់ក្រុមមេធាវីការពារក្តីថា បញ្ជីឈ្មោះសាក្សីបឋមរបស់អង្គជំនុំជម្រះសាលាដំបូងរំលោភលើគោលការណ៍នៃសមភាពក្នុងការតទល់គ្នាក្នុងរឿងក្តី ពីព្រោះបញ្ជីនេះខកខានមិនបានធានាថាត្រូវមាន "សមមាត្រជាមូលដ្ឋាន" រវាងពេលវេលា និងចំនួនសាក្សី ដែលត្រូវផ្តល់ឱ្យទៅភាគីទាំងអស់នោះ[65] គឺជាការអះអាងដែលមិនត្រឹមត្រូវក្នុងការសន្មតថា "សមាមាត្រ" មានន័យថាជាសមភាពដាច់ខាតនោះ។ ផ្ទុយមកវិញ៖

> *គោលការណ៍នៃសមភាពក្នុងការតទល់គ្នាក្នុងរឿងក្តី ពុំផ្តល់សិទ្ធិជាក់លាក់ឱ្យជនជាប់ចោទមានពេលវេលាស្មើគ្នា ឬ សាក្សីដូចគ្នាទៅនឹងអយ្យការឡើយ ហើយសមាមាត្រជាមូលដ្ឋាន ពោលគឺពុំមែនសមភាពតាមបែបគណិតសាស្ត្រនោះទេ ជាទូទៅ គឺគ្របដណ្តប់លើទំនាក់ទំនងរវាងពេលវេលា និងចំនួនសាក្សីដែលផ្តល់ជូនដល់ភាគីនីមួយៗ*[66]។

29. លើសពីនេះ នៅក្នុងបរិបទពិសេសនៃកិច្ចដំណើរការរបស់ អ.វ.ត.ក សហព្រះរាជអាជ្ញាសន្និដ្ឋានថាការកំណត់សាក្សីដោយក្រុមមេធាវីការពារក្តីថា "បែងចែក" ទៅម្ខាង ហើយដែលអាចគាំទ្រទាំងភស្តុតាងដាក់បន្ទុក ឬ ដោះបន្ទុក គឺជាការច្របាច់ចូលគ្នារវាងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ជាមួយនឹងបណ្តាកិច្ចដំណើរការនីតិវិធីរបស់សាលាក្តីអន្តរជាតូបនីយកម្ម និងតុលាការនៃប្រព័ន្ធច្បាប់ខំមិនឡផ្សេងទៀត[67]។ ក្រៅពីតុលាការនៃប្រព័ន្ធច្បាប់ខំមិនឡ ដែលសាក្សីផ្តល់សក្ខីកម្មគាំទ្រអយ្យការ ឬ ក្រុមមេធាវីការពារក្តី មានតែអង្គជំនុំជម្រះប៉ុណ្ណោះជាអ្នកកំណត់សាក្សីណាដែលខ្លួនគួរស្តាប់សក្ខីកម្ម និងជាអ្នក

---

[64] រឿងក្តី *Taylor* លេខកំណត់សម្គាល់ ៦១ *ខាងលើ* ត្រង់កថាខណ្ឌ ១៨។

[65] សំណើសុំលេខ **E212** លេខកំណត់សម្គាល់ ១ *ខាងលើ* ត្រង់កថាខណ្ឌ ២១។

[66] *រដ្ឋអាជ្ញា ទល់នឹង និង Issa Sesay ជនផ្សេងទៀត* រឿងក្តីលេខ SCSL-04-15-T ដីកាសម្រេចដោយថាហេតុពាក់ព័ន្ធនឹងការរៀបចំ និងការចាប់ផ្តើមរឿងក្តីរបស់ក្រុមមេធាវីការពារក្តី (អង្គជំនុំជម្រះសាលាដំបូងទី I)របស់ SCSLចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៧ ត្រង់ទំព័រទី៤។

[67] *ដូចខាងលើ*។

កោះហៅសាក្សីឱ្យមកបង្ហាញខ្លួន[68]។ អង្គជំនុំជម្រះមានតួនាទីកំណត់សក្ខីកម្មដែលនាំមកនូវការស្វែងរកការពិត ពុំមែនមានតួនាទីស្ថាបនាទម្រង់ណាមួយនៃសមាមាត្រតាមបែបគណិតសាស្ត្ររវាងភាគីនៃរឿងក្តី ដោយផ្អែកតាមបញ្ជីដែលបានស្នើសុំរបស់ភាគីនៃរឿងក្តីឡើយ[69]។

30. តាមទម្លាប់ សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិកំណត់ "ពេលវេលា និងមធ្យោបាយសមស្រប" ដែលត្រូវការសម្រាប់ធ្វើការការពារខ្លួន ដោយផ្អែកលើមូលដ្ឋាននៃកាលៈទេសៈនៃរឿងក្តីនីមួយៗ និង "ដោយពិនិត្យលើកាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីធានាថា ការជំនុំជម្រះមានលក្ខណៈ យុត្តិធម៌ និងឆាប់រហ័ស"[70]។ នៅចំពោះមុខ អ.វ.ត.ក វាជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការចាត់ទុកអ្វីមួយថាជា "ពេលវេលា និងមធ្យោបាយសមស្រប" សម្រាប់ការបង្ហាញរឿងក្តី ជាពាក្យពេចន៍នៃសមភាពក្នុងការតទល់គ្នាក្នុងរឿងក្តី។ ផ្អែកតាមមូលដ្ឋាននេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា គោលការណ៍នៃសមភាពក្នុងការតទល់គ្នាក្នុងរឿងក្តី ពុំអាចផ្តល់ជាមូលដ្ឋានគតិយុត្តចំពោះការអះអាងរបស់ក្រុមមេធាវីការពារក្តីថា ភាគីត្រូវធ្វើសេចក្តីសន្និដ្ឋាននៅក្នុងសវនាការជាសាធារណៈអំពីខ្លឹមសារ នៃបញ្ជីឈ្មោះដែលបានស្នើសុំ។

## ឃ. សិទ្ធិក្នុងការការពារខ្លួន ពុំតម្រូវឱ្យមានសវនាការសម្រាប់ឱ្យក្រុមមេធាវីការពារក្តីធ្វើសន្និដ្ឋានដោយផ្ទាល់មាត់អំពីខ្លឹមសារនៃបញ្ជីឈ្មោះដែលបានស្នើសុំនោះទេ

31. សហព្រះរាជអាជ្ញាទទួលស្គាល់សិទ្ធិរបស់ជនជាប់ចោទក្នុងការការពារខ្លួន ក្នុងក្របខ័ណ្ឌនៃកិច្ចដំណើរការនីតិវិធី "ដោយយុត្តិធម៌ និងនៅចំពោះមុខ" ដែលអាច "ជំនុំជម្រះក្នុងរយៈពេលមួយសមស្រប"[71]។ សាលាក្តីអន្តរជាតូបនីយកម្មនានាបានទទួលស្គាល់ថា អង្គជំនុំជម្រះរបស់ខ្លួនមានលទ្ធភាពគោរពសមភាពក្នុងការតទល់គ្នាក្នុងរឿងក្តីរវាងភាគី និងសិទ្ធិពេញលេញរបស់ជនជាប់ចោទក្នុងការការពារខ្លួន ប៉ុន្តែ នៅក្នុងពេលជាមួយគ្នានោះ បានបង្គាប់ឱ្យក្រុមមេធាវីការពារក្តី កាត់បន្ថយបញ្ជីឈ្មោះសាក្សី

[68] វិធាន ៨៤(២) និងវិធាន ៨១ នៃវិធានផ្ទៃក្នុង។

[69] វិធាន ៨១(៣) នៃវិធានផ្ទៃក្នុង។

[70] រឿងក្តី *Taylor* លេខកំណត់សម្គាល់ ៦១ *ខាងលើ* ត្រង់កថាខណ្ឌ ១៩។

[71] វិធាន ២១ នៃវិធានផ្ទៃក្នុង។

របស់ខ្លួនឱ្យបានច្រើន[72]។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR ថែមទាំងបានកត់សម្គាល់ថា "ការការពារក្ដីឱ្យបានពេញលេញ ជាធម្មតា ចាំបាច់ត្រូវមានរយៈពេលខ្លី និងសាក្សីតិចតួចជាងការបង្ហាញរឿងក្ដីរបស់អយ្យការ"[73]។

32. សហព្រះរាជអាជ្ញាមិនអាចឯកភាពតាមការលើកឡើងរបស់មេធាវីការពារក្ដីដែលថា សិទ្ធិក្នុងការការពារខ្លួនរបស់ជនជាប់ចោទត្រូវបានរំលោភបំពាន ដោយសារតែបញ្ជីឈ្មោះសាក្សីបណ្ដោះអាសន្នកម្រិតឱ្យមេធាវីការពារក្ដីរបស់ជនជាប់ចោទត្រឹមតែធ្វើ "ការសួរដេញដោលរបៀប ការពារខ្លួន" ប៉ុណ្ណោះ ឬហាមឃាត់មេធាវីការពារក្ដីមិនឱ្យ "ស្វែងយល់អំពីការបកស្រាយ ហេតុការណ៍ទាំងឡាយខាងក្រៅក្របខ័ណ្ឌនៃរបាយការណ៍របស់ភាគីព្រះរាជអាជ្ញាទេ"[74]។ ការអះអាងទាំងអស់នេះ មិនយកចិត្តទុកដាក់នឹងចរិតលក្ខណៈសំខាន់ពីរនៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ឡើយៈ (១) វិធានផ្ទៃក្នុងមិនគាំទ្រនីតិវិធីនៃការសួរដេញដោលដែលមាននៅតុលាការ ឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀតឡើយ[75] ប៉ុន្តែគ្រប់ភាគីទាំងអស់មានសិទ្ធិដូចគ្នា ក្នុងការសួរសំណួរ ទៅកាន់សាក្សីទាំងឡាយ នៅពេលមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះសាលាដំបូង[76]។ និង (២) បញ្ជីឈ្មោះសាក្សីបណ្ដោះអាសន្នផ្ទុះ

---

[72] *សូមមើល ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Augustin Ngirabatware* រឿងក្ដីលេខ ICTR-99-54-T សេចក្ដីសម្រេចលើញត្តិរបស់ក្រុមមេធាវីការពារក្ដីស្នើសុំឱ្យពិចារណាឡើងវិញ ឬ បញ្ជាក់លើបណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចធ្វើឡើង ដោយផ្ទាល់មាត់នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១១ និងលើការកាត់បន្ថយបញ្ជីឈ្មោះសាក្សីរបស់ក្រុមមេធាវីការពារក្ដី (អង្គជំនុំជម្រះសាលាដំបូងទី II នៃតុលាការ ICTR) ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ ត្រង់កថាខណ្ឌ ៥៦។ *រដ្ឋអាជ្ញា ទល់នឹង Léonidas Nshogoza* រឿងក្ដីលេខ ICTR-07-91-T សេចក្ដីសម្រេចលើញត្តិរបស់ក្រុមមេធាវីការពារក្ដីស្នើសុំឱ្យពិចារណា ឡើងវិញលើដីកាបង្គាប់បន្ថែមរបស់អង្គជំនុំជម្រះឱ្យក្រុមមេធាវីការពារក្ដីកាត់បន្ថយបញ្ជីឈ្មោះសាក្សី (អង្គជំនុំជម្រះសាលា ដំបូងទី III នៃតុលាការ ICTR) ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ត្រង់កថាខណ្ឌ ៨។ *រដ្ឋអាជ្ញា ទល់នឹង Simon Bikindi* រឿងក្ដីលេខ ICTR-2001-72-T សេចក្ដីសម្រេចលើញត្តិរបស់ក្រុមមេធាវីការពារក្ដី ស្នើសុំដាក់បញ្ជីឈ្មោះសាក្សី ដែលបានស្នើឡើង និងសេចក្ដីប្រកាសអំពីអង្គហេតុ និងអង្គច្បាប់ ដែលបានព្រមព្រៀងគ្នា និងដែលបានតវ៉ា (អង្គជំនុំជម្រះសាលាដំបូងទី III នៃតុលាការ ICTR) ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០៧ ត្រង់កថាខណ្ឌ ៧។

[73] ករណី Ngirabatware *ដូចខាងលើ* ត្រង់កថាខណ្ឌ ៤៦។

[74] ឯកសារ **E212** សំណើសុំ កំណត់សម្គាល់ ចំណុច ១ *ខាងលើ* ត្រង់កថាខណ្ឌ ១៩។

[75] ឯកសារ **E1/60.1** ប្រតិចារឹក ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ១១ បន្ទាត់១៥។

[76] វិធាន ៨៥(១) នៃវិធានផ្ទៃក្នុង។

បញ្ជាំងជាចាំបាច់ អំពីការយល់ឃើញរបស់អង្គជំនុំជម្រះ សាលាដំបូងថា តើសក្ខីកម្មណាមួយដែលនឹងមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត មិនមែនអំពីរបាយការណ៍ដែលធ្វើឡើងដោយភាគីនីមួយៗនោះទេ[77]។

33. មូលហេតុនេះ សហព្រះរាជអាជ្ញាលើកឡើងថា សិទ្ធិក្នុងការការពារខ្លួនមិនបង្កើតបានជាមូលដ្ឋានគតិយុត្តិដើម្បីគាំទ្រការអះអាងរបស់មេធាវីការពារក្តីដែលថា អង្គជំនុំជម្រះត្រូវតែអនុញ្ញាតឲ្យមានការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ស្តីពីខ្លឹមសារនៃបញ្ជីឈ្មោះសាក្សីដែលបានស្នើសុំឡើយ។

**ង.សិទ្ធិក្នុងការទទួលបានសវនាការ *ជាសាធារណៈ*របស់ជនជាប់ចោទមិនមានន័យថាជាសវនាការ *ផ្ទាល់មាត់*តែមួយមុខឡើយ**

34. គោលជំហរស៊ីសង្វាក់គ្នារបស់សហព្រះរាជអាជ្ញា ក៏គាំទ្រដល់ការផ្សាយជាសាធារណៈនៃកិច្ចដំណើរការនីតិវិធីសវនាការផងដែរ ដោយស្របតាមច្បាប់ និងវិធានផ្ទៃក្នុង អ.វ.ត.ក ជាធរមាន ផងដែរ[78]។ ដូចដែលបានពិភាក្សាខាងលើ ការស្តាប់ចម្លើយនានានៅចំពោះមុខអង្គជំនុំជម្រះ មិន *ចាំបាច់តម្រូវឲ្យមានទឡ្ហីករណ៍ផ្ទាល់មាត់ឡើយ*។ ជាការពិត ការប្រើប្រាស់ទឡ្ហីករណ៍ផ្ទាល់មាត់ ដើម្បីដោះស្រាយវិវាទផ្នែកនីតិវិធីគ្រប់យ៉ាងរវាងភាគីនានា នឹងជាការផ្ទុយទៅនឹងគោលការណ៍គ្រឹះ នៃវិធានផ្ទៃក្នុងពោលគឺថា ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះ វិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប[79]។

35. សហព្រះរាជអាជ្ញាទទួលស្គាល់អំពីសារៈសំខាន់ទ្វេរដងដែលថា សវនាការជាសាធារណៈធ្វើឡើងដើម្បីសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី អ.វ.ត.ក និងសិទ្ធិរបស់ជនជាប់ចោទ ទាំងពីរយ៉ាងនេះ គឺដើម្បីធានាអំពី "ការផ្តល់ព័ត៌មានដល់សាធារណៈជនអំពីវិវឌ្ឍនភាពនៃដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ"[80] និងដើម្បីអនុញ្ញាតឲ្យធ្វើការពិនិត្យពិច័យពីសាធារណជន និងសាព័ត៌មាន ក្នុងការរួម

---

[77] វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

[78] វិធាន ៨៥(១) នៃវិធានផ្ទៃក្នុង។ ឯកសារ E1/7.1 ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីសវនាការ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ៣៨។

[79] វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

[80] វិធាន ៥៤ នៃវិធានផ្ទៃក្នុង។

ចំណែកដល់ភាពយុត្តិធម៌នៃការជំនុំជម្រះក្តី[81]។ តែទោះជាយ៉ាងណាក្តី ផ្ទុយទៅនឹងគោលជំហររបស់មេធាវីការពារក្តីដែលថា សវនាការ "ត្រូវតែបញ្ចូលនូវទទ្បីករណ៍សំខាន់ៗ"[82] សហព្រះរាជអាជ្ញាសូមលើកឡើងថា ការសម្រេចថា សវនាការជាសាធារណៈនឹងបញ្ចូល ឬនឹងមិន បញ្ចូលនូវទទ្បីករណ៍ផ្ទាល់មាត់ក្នុងវិសាលភាពណាមួយនោះ នៅតែស្ថិតក្នុងឆន្ទានុសិទ្ធិគ្រប់គ្រង សវនាការរបស់អង្គជំនុំជម្រះដដែល[83]។

**ច. ក្នុងករណីមានហានិភ័យដែលអាចកើតឡើងទៅលើសិទ្ធិទទួលបាននូវការជំនុំជម្រះ ក្តីប្រកបដោយភាពយុត្តិធម៌របស់ជនជាប់ចោទ ដំណោះស្រាយសមស្របគឺជាសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ មិនមែនជាសវនាការជាសាធារណៈផ្ទាល់មាត់ឡើយ**

36. សហព្រះរាជអាជ្ញាមិនឯកភាពជាមួយនឹងការអះអាងរបស់មេធាវីការពារក្តីទេដែលថា សមភាពក្នុងការតទល់គ្នាក្នុងរឿងក្តី សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ ឬ ក្នុងការការពារខ្លួន តម្រូវឲ្យមានសវនាការ ស្របតាមវិធានផ្ទៃក្នុង ៨០ *ស្ទួន* ដើម្បីអនុញ្ញាតឲ្យមេធាវីការពារក្តីធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ស្តីពីខ្លឹមសារនៃបញ្ជីឈ្មោះសាក្សី ដែលខ្លួនបានស្នើសុំនោះឡើយ[84]។ ប្រសិនបើអង្គជំនុំជម្រះកំណត់អំពីហានិភ័យណាមួយ ដែលអាចកើតឡើងទៅលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តី ប្រកបដោយភាពយុត្តិធម៌របស់ជនជាប់ចោទ នៅក្នុងកាលៈទេសៈនានា សហព្រះរាជអាជ្ញាសូមលើកឡើងដោយគោរពថា ការចាត់វិធានការសមរម្យជាបឋមគឺថា អង្គជំនុំជម្រះគួរចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរស្តីអំពីការសម្រេចជ្រើសរើសយកសាក្សី និងអ្នក

[81] រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Zejnil Delalić et al.*, សំណុំរឿង IT-96-21-T សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា សុំចាត់វិធានការការពារចំពោះសាក្សីរបស់រដ្ឋអាជ្ញា ដែលមានរហស្សនាមថា "B" រហូតដល់ "M" (អង្គជំនុំជម្រះសាលាដំបូង របស់តុលាការ ICTY) ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៧ ត្រង់កថាខណ្ឌ ៣៤។

[82] ឯកសារ **E212** សំណើសុំ កំណត់សម្គាល់ ចំណុច ១ *ខាងលើ* ត្រង់កថាខណ្ឌ ១៤។

[83] វិធាន ៨៥(១) នៃវិធានផ្ទៃក្នុង ("ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវដឹកនាំកិច្ចដំណើរការនីតិវិធី និងជួយសម្រួលដល់ការធ្វើអន្តរាគមន៍របស់ភាគីផ្សេងទៀត។ ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឲ្យប្រព្រឹត្តទៅ បានដោយសេរី។ ដោយមានការពិគ្រោះយោបល់ជាមួយភាគីផ្សេងទៀត ប្រធានសវនាការអាចបដិសេធនូវរាល់នីតិវិធីដែល នាំឲ្យមានការពន្យារពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត")។

[84] ឯកសារ **E212** សំណើសុំ កំណត់សម្គាល់ ចំណុច ១ *ខាងលើ* ត្រង់កថាខណ្ឌ ១៨។

ជំនាញ ដែលស្នើឡើងដោយមេធាវីការពារក្តី ហើយនៅទីបញ្ចប់នៃការជំនុំជម្រះនៅដំណាក់កាលទីមួយ ផ្តល់ឱកាសឲ្យមេធាវីការពារក្តីដាក់សាណាជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ថាតើគួរមានការស្តាប់សាក្សីបន្ថែមទៀត ឬក៏មិនមាន សម្រាប់ឲ្យជនជាប់ចោទអនុវត្តសិទ្ធិនៃការជំនុំជម្រះក្តីដោយយុត្តិធម៌របស់គាត់។

## IV. **សំណើ**

37. អាស្រ័យដោយមូលហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះ សូមមេត្តា

ក. បដិសេធសំណើសុំទាំងមូល។

ខ. ចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរអំពីការជ្រើសរើសសាក្សី និងអ្នកជំនាញដែលបានស្នើឡើងដោយមេធាវីការពារក្តី និង

គ. ផ្តល់ឱកាសឲ្យមានការដាក់សារណាជាលាយលក្ខណ៍អក្សរពីក្រុមមេធាវីការពារក្តីនៅចុងបញ្ចប់នៃដំណាក់កាលដំបូងនៃសវនាការទាក់ទិននឹងសាក្សីបន្ថែមដែលខ្លួនពិចារណាថា ចាំបាច់ក្នុងការធានាឲ្យជនជាប់ចោទទទួលបាននូវការកាត់ក្តីដោយយុត្តិធម៌។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៥ ខែ កក្កដា ឆ្នាំ ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | | [signature] |
| | **លោក** William SMITH<br>សហព្រះរាជអាជ្ញារង | | [signature] |